ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តបាត់ដំបង

គុណភាពរដ្ឋប្បវេណី
សំណុំរឿងរដ្ឋប្បវេណីលេខ៖ ៥១៦
ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២
សញ្ញាណរឿងក្តី៖ ទាមទារប្រាក់
**សាលក្រមលេខ៖ ១២៨ "ឃ"**
**ចុះថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០២៣**

# គោរពនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តបាត់ដំបង

• បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ ដោយមានសមាសភាពចូលរួមដូចខាងក្រោម:

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមនៃសាលាដំបូងខេត្តបាត់ដំបង·

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តបាត់ដំបង

**ចេញសាលក្រមដែលមានខ្លឹមសារដូចតទៅ៖**

**ដើមចោទ៖**

**ដើមចោទ៖** [redacted] (អតីតគ្រឹះស្ថានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ [redacted] មានអាសយដ្ឋាន [redacted] ដោយមានប្រធានសាខាធនាគារ លោក [redacted] ស៊ីដេត ជាប្រធានសាខាស្រុករតនមណ្ឌលនៃខេត្តបាត់ដំបង។

អ្នកតំណាងដោយអាណត្តិឲ្យដើមចោទ៖ លោកមេធាវី [redacted] មានអាសយដ្ឋាននៅការិយាល័យ [redacted]។

**សហចុងចម្លើយ៖**

**១.ឈ្មោះ** [redacted] **សាវឿន** ភេទប្រុស កើតថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៥៩ មានទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] (ជាប្តី) ។

២.ឈ្មោះ [redacted] **សាម៉ុន** សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ [redacted] (ជាប្រពន្ធ)។

-អ្នកតំណាងដោយអាណត្តិឲ្យចុងចម្លើយ៖ លោកមេធាវី [redacted] អត្តលេខ ៦០៤ និងមេធាវី [redacted] មានការិយាល័យ [redacted]។

## អង្គហេតុ និងចំណុចវិវាទ

### ក- ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ៖

១-បង្គាប់ឲ្យចុងចម្លើយបង់៖

១.១ប្រាក់ដើមចំនួន **១១៦៦៦៦ (មួយសែនមួយម៉ឺនប្រាំមួយពាន់ប្រាំមួយរយហុកសិបប្រាំមួយ) ដុល្លាអាមេរិក ។**

១.២.ការប្រាក់ចំនួន **២៧៩៩ $ (ពីរពាន់ប្រាំពីររយកៅសិបប្រាំបួន) ដុល្លាអាមេរិក** គឺជាការប្រាក់ត្រូវគិតថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២១ នៃអត្រាការប្រាក់ ១,២ (មួយក្បៀសពីរ) ភាគរយក្នុងមួយខែ នៃប្រាក់ដើមដែលនៅជំពាក់។

១.៣.ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច គិតពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១ លើអត្រាការប្រាក់ ៣ % (បីភាគរយ) ក្នុងមួយខែ នៃប្រាក់ដើមដែលនៅជំពាក់ រហូតដល់ថ្ងៃសងគ្រប់ចំនួន ។

២. ទាមទារសំណងជំងឺចិត្ត និងសំណងការខូចខាតចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល។

៣. ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់ចុងចម្លើយ។

៤. សាលក្រមនេះ អាចអនុវត្តជាបណ្ដោះអាសន្នបាន។

### ខ. ដំណើររឿង និងចំណុចវិវាទ៖

#### ខ.១-ការសង្ខេបអំពីរឿងក្តី

កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៨ ដើមចោទ និងចុងចម្លើយបានចុះកិច្ចសន្យាខ្ចីបរិភោគក្នុងចំនួនទឹកប្រាក់ ១៥០,០០០ (មួយសែនប្រាំម៉ឺន) ដុល្លាអាមេរិក ។ នៅក្នុងកិច្ចសន្យានេះ គូភាគីបានព្រមព្រៀងគ្នាជាលាយល័ក្ខណ៍អក្សរអំពីការបង់ការប្រាក់ចំនួន ១.២% (មួយក្បៀសពីរ) ភាគរយក្នុងមួយខែ និងសំណងនៃការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចចំនួន ៣៦ % (សាមសិបប្រាំមួយ) ភាគរយ ក្នុងមួយឆ្នាំនៃប្រាក់កម្ចីក្នុងចំនួន ១៥០,០០០ (មួយសែនប្រាំម៉ឺន) ដុល្លារអាមេរិក ខាងលើ។

នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៨ ដើមចោទបានប្រគល់ប្រាក់ចំនួន ១៥០,០០០ (មួយសែនប្រាំម៉ឺន) ដុល្លារអាមេរិក ឲ្យទៅចុងចម្លើយ ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគខាងលើ។

នៅក្នុងកិច្ចសន្យានេះ ចុងចម្លើយបានយល់ព្រមឲ្យដើមចោទចាត់ចែងវត្ថុដែលបានដាក់ធានា និង/ឬវត្ថុផ្សេងទៀត ដើម្បីទូទាត់សិទ្ធិលើបំណុល និងសំណងការខូចខាតផ្សេងទៀត ក្រោយផុតរយៈពេល ០២ (ពីរ) ខែនៃការមិនអនុវត្តកាតព្វកិច្ចដែលជាលះបង់ផលប្រយោជន៍នៃការកំណត់ពេលសង ហើយកាលបរិច្ឆេទនៃការសងប្រាក់កម្ចី និង សំណងនៃការខូចខាតមកដល់ភ្លាម។ នៅថ្ងៃទី**២៦ ខែកក្កដា ឆ្នាំ២០២១** បានកន្លងផុតទៅ។ មុនពេលដាក់ពាក្យបណ្ដឹងនេះ នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១ ដើមចោទបានចេញលិខិតជូនដំណឹងឲ្យដល់ចុងចម្លើយ ហើយចុងចម្លើយបានចូលរួមដោះស្រាយ និងយល់ព្រមបង់ការប្រាក់កម្ចីយឺតយ៉ាវត្រឹមថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ ឲ្យដល់ដើមចោទ ប៉ុន្តែដល់កាលបរិច្ឆេទកំណត់ត្រូវសងប្រាក់ ចុងចម្លើយមិនអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួនឡើយ។ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ ដើមចោទបានចេញលិខិតអញ្ជើញរបស់មេធាវីឲ្យដល់ចុងចម្លើយ ហើយចុងចម្លើយមិនចូលរួមដោះស្រាយដោយផ្ទាល់ទេ ដោយឲ្យកូន ០២ (ពីរ) នាក់ ជាអ្នកតំណាងចូលរួមដោះស្រាយជំនួស ។ នៅក្នុងកំណត់ហេតុដោះស្រាយបំណុល ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២ កូនរបស់ចុងចម្លើយយល់ព្រមបង់ផ្ដាច់ឲ្យដល់ធនាគារទាំងប្រាក់ដើម និងការប្រាក់នៅត្រឹមថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ ហើយធនាគាបានយល់ព្រមលើកលែង ៣០% (សាបសិប) ភាគរយនៃការប្រាក់ឲ្យដល់ចុងចម្លើយ។ ប៉ុន្តែដល់កាលបរិច្ឆេទកំណត់សងមកដល់ ចុងចម្លើយមិនអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួនជាថ្មីម្តងទៀត។ ដើមចោទបានធ្វើការទំនាក់ទំនងទាមទារប្រាក់កម្ចីពីចុងចម្លើយតាមគ្រប់មធ្យោបាយ និងជូនដំណឹងជាស់តឿនជាច្រើនលើកជាច្រើនសារមកហើយ ប៉ុន្តែចុងចម្លើយនៅតែបន្តនូវសកម្មភាពគេចវេស និងមិនបង់ប្រាក់ឲ្យដើមចោទតាមកាលកំណត់ឡើយ។ សកម្មភាពមិនអនុវត្តកាតព្វកិច្ចឲ្យទាន់ពេលកំណត់ត្រូវអនុវត្ត គឺជាការបំពានចំពោះកិច្ចសន្យាធ្ងន់ធ្ងរ

ដែលមានកំណត់នៅក្នុងច្បាប់ និងធ្វើឲ្យខាតបង់ផលប្រយោជន៍ និងប៉ះពាល់ធ្ងន់ធ្ងរដល់ប្រតិបត្តិការអាជីវកម្មរបស់ដើមចោទក្នុងការប្រមូលប្រាក់កម្ចីត្រឡប់មកវិញ។

**ខ.២ ការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទៈ**

*** នៅក្នុងនីតិវិធីត្រៀសម្រាប់ការទាញហេតុផល៖**

**-អ្នកតំណាងដោយអាណត្តិឲ្យដើមចោទ លោកមេធាវី [redacted] បានធ្វើសេចក្តី ថ្លែងការណ៍ ថាៈ** ខ្ញុំសូមរក្សាការទាមទារដដែល ដូចក្នុងពាក្យបណ្តឹង និងនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញ ហេតុផលដដែល។ ប៉ុន្តែសូមធ្វើការកែប្រែត្រង់ចំណុចដូចខាងក្រោមៈ

១-ចំពោះប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច (ការប្រាក់យឺតយ៉ាវ) គឺត្រូវគិតពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ លើអត្រាការប្រាក់ ៣ (បី) ភាគរយ ក្នុងមួយខែ នៃប្រាក់ដើមដែលនៅជំពាក់ រហូតដល់ថ្ងៃ សងគ្រប់ចំនួន ។ ដូច្នេះចំពោះការទាមទារចំណុចទី១ នៃពាក្យបណ្តឹង ដែលបានកំណត់ចំនួន ទឹកប្រាក់ ៤៨៩៩៩ ដុល្លាអាមេរិក ត្រូវលុបចោលវិញ និងកាលបរិច្ឆេទ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ ត្រូវលុបចោលផងដែរ។

២-ចំណុចទាក់ទងនឹងការប្រាក់ចំនួន ២៧៩៩ (ពីរពាន់ប្រាំពីររយកៅសិបប្រាំបួន) ដុល្លារអាមេរិក គឺត្រូវគិតថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ ដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ នៃអត្រាការប្រាក់ ១,២ (មួយក្បៀសពីរ) ភាគរយ ក្នុងមួយខែ នៃប្រាក់ដើមដែលនៅជំពាក់ ។ ចំពោះមូលហេតុ និងអង្គហេតុនៃការទាមទារ គឺខ្ញុំបាទសូមរក្សានៅដដែល។

**-ភាគីអ្នកតំណាងដោយអាណត្តិឲ្យដើមចោទឈ្មោះ [redacted] បានធ្វើសេចក្តីថ្លែងការណ៍ថាៈ** ការលើកឡើងរបស់ចុងចម្លើយទាក់ទងនឹងអត្រាការប្រាក់ ចំនួន ១,២ ភាគរយ នោះ គឺមិនត្រឹមត្រូវទេ ដោយសារតែមានប្រកាសបានកំណត់ចំនួន ការប្រាក់ ចំនួន ១៨ ភាគរយក្នុងមួយឆ្នាំ (ដោយគិតជាខែមានចំនួន ១,៥ ភាគរយ ក្នុង មួយខែ) ។ ដូច្នេះ ការទាមទាររបស់ដើមចោទ គឺត្រឹមត្រូវតាមប្រកាសលេខ ១២៨-កយ.ប្រក/១៤ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ របស់ក្រសួងយុត្តិធម៌។ចំពោះការថ្លែងការណ៍របស់ចុងចម្លើយ ទាក់ទងនឹង ការប្រាក់យឺតយ៉ាវ ដោយសារតែកិច្ចសន្យានេះ ជាកិច្ច សន្យាព្រមព្រៀងគ្នា ដោយគូភាគីបានព្រមព្រៀងនឹង ការប្រាក់យឺតយ៉ាវ គឺមានចំនួន ៣៦ ភាគរយក្នុងមួយឆ្នាំ (៣ ភាគរយ ក្នុងមួយខែ)។ ហេតុនេះ ការទាមទារចំណុចនេះ គឺមានអានុភាពដោយសារមានសំណើរ និងស្ទីការត្រូវគ្នា (តាមមាត្រា ៣៣៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី) និងគោរពតាមគោលការណ៍ ស្វ័យភាពឆន្ទៈរបស់ បុគ្គល ឯកជន មាត្រា ៣ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណី។ ចំពោះការ ទាមទារសំណងការខូចខាត និងជំងឺចិត្ត ចំនួន ៤០,០០០,០០០ រៀល ដោយហេតុថា ដើមចោទ បានចំណាយ ទៅលើសេវាមេធាវី ការធ្វើដំណើរចុះឡើង ការចំណាយការហូបចុកស្នាក់នៅ ជាអាទិ៍ ដូច្នេះ ដើមចោទនៅតែរក្សាការ ទាមទារដដែល។

***នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់**

**-ភាគីអ្នកតំណាងដោយអាណត្តិឲ្យដើមចោទឈ្មោះ [redacted] បានធ្វើសេចក្តីថ្លែងការណ៍ ថាៈ** ខ្ញុំសូមរក្សាការទាមទារ និងអង្គហេតុដូចក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកមុនដដែរ។ ចុងចម្លើយបានទទួលស្គាល់ប្រាក់ដើម។ ខ្ញុំសូមបញ្ជាក់ថា នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១ ដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ ចុងចម្លើយបានខកខាន ក្នុងការបង់ ការប្រាក់ ។ នៅក្នុងកិច្ចសន្យាខ្ចីបរិភោគប្រការ ៧ បានកំណត់ច្បាស់លាស់ពីប្រាក់យឺតយ៉ាវ ។ ខ្ញុំសូមទាមទារសំណងការខូចខាតដដែរ ដោយសារតែខាងធនាគារ បានចំណាយលើសេវាមេធាវី និងការធ្វើដំណើរចុះឡើងជាច្រើនលើក។ ចុងចម្លើយមានចេតនាគេសវេសក្នុងការបង់សងមកធនាគារ ហើយវាប៉ះពាល់ដល់ដើមចោទយ៉ាងធ្ងន់ធ្ងរ ដូច្នេះការទាមទាររបស់ដើមចោទ មានលក្ខណៈត្រឹមត្រូវតាមច្បាប់។

**-ភាគីអ្នកតំណាងដោយអាណត្តិឲ្យដើមចោទឈ្មោះ [redacted] បានធ្វើសេចក្តីថ្លែងការណ៍នៅថាៈ** យើងខ្ញុំបានតស្តុតាងដាក់ជូនតុលាការពិនិត្យ ដូចជា កិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាហ៊ីប៉ូតែកក , តារាងបង់ប្រាក់ និងប្រវត្តិនៃការបង់ប្រាក់។ ខាងចុងចម្លើយក៏បានទទួលស្គាល់ប្រាក់ដើម។ ចំពោះការប្រាក់ចំនួន ២៧៩៩

ដុល្លារអាមេរិក គិតរយៈពេល ២ ខែ គិតពី ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២១ ។ ក្រោយមកយើងគិតលើប្រាក់ឃឹតយ៉ាវ ៣ ភាគរយ ក្នុងមួយខែ គឺជាកិច្ចសន្យាព្រមព្រៀង និងគោរពគោលការណ៍លើស្វ័យភាពភាគី។ ដូច្នេះការកំណត់ អត្រាការប្រាក់ដែលខាងធនាគារគឺស្របតាមច្បាប់ និងស្របតាមការព្រមព្រៀងគូភាគី។ ចុងចម្លើយបានខកខាន អនុវត្តកាតព្វកិច្ច ២ ឆ្នាំហើយ។ ការប្រាក់ ១៤ ភាគរយ ក្នុងមួយឆ្នាំ គឺត្រឹមត្រូវតាមច្បាប់ កំណត់។ ការកំណត់ ប្រាក់ឃឹតយ៉ាវ ក៏កើតឡើងដោយការព្រមព្រៀងគ្នា គ្មានការបង្ខិត បង្ខំឡើយ។ ចំណែកករណីប្រធានស័ក្ក មាត្រា ៣៩៩ បានកំណត់ច្បាស់អំពីការប្រាក់នេះ។

**ខ.៣. ការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយ ៖**

**-ភាគីអ្នកតំណាងដោយអាណត្តិឲ្យចុងចម្លើយ លោកមេធាវី [redacted] បានធ្វើសេចក្តីថ្លែងការណ៍ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា៖** កូនក្តីខ្ញុំទទួលស្គាល់តែប្រាក់ដើមតែប៉ុណ្ណោះ ដូច្នេះ ខ្ញុំបាទមិនធ្វើការកែប្រែលើចំនួនប្រាក់ដើមនោះទេ ។ តែចំពោះចំណុចទី១ ការទាមទារការប្រាក់ឃឹតយ៉ាវ និងការប្រាក់ កូនក្តីខ្ញុំបាទសូមបដិសេធ។ ចំណុចទាមទារសំណងជំងឺចិត្ត និងសំណងការខូចខាតចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល ក៏កូនក្តីខ្ញុំបដិសេធផងដែរ។

ចំពោះការបដិសេធទាក់ទងនឹងការប្រាក់ ដោយសារតែអត្រាការប្រាក់ដែលធនាគារ កំណត់ជាមួយនឹងកូនក្តីខ្ញុំ មានអត្រាប្រាក់ខ្ពស់ ដោយខាងធនាគារគិតចំនួន ១,២ ភាគរយក្នុងមួយខែ ដោយគិតជាឆ្នាំមានចំនួន ១៤,៤ (ដប់បួនក្បៀសបួន) ភាគរយក្នុងមួយឆ្នាំ ។

ចំពោះការប្រាក់ឃឹតយ៉ាវ ដែលដើមចោទទាមទារមានចំនួន ៣ ភាគរយក្នុងមួយខែ នៃប្រាក់ ដើមនោះ គឺមានចំនួនលើសច្បាប់កំណត់។

ទាក់ទងនឹងកូនក្តីខ្ញុំខកខានបង់ប្រាក់ជំពាក់ ដោយសារតែស្ថានភាពកន្លងមក កូនក្តីខ្ញុំមានមុខរបរដាំដំណាំតាងែន ហើយគាត់មានបញ្ហាជួបប្រទះនឹងបញ្ហាគ្មានទីផ្សារ និងមានការបិទព្រំដែន នៅក្នុងអំឡុងពេលដែលមានរីករាលដាលកូវីត ១៩ ជាហេតុដែលធ្វើឱ្យកូនក្តីខ្ញុំបានខកខានបង់ប្រាក់ជូនធនាគារ។

**-ភាគីអ្នកតំណាងដោយអាណត្តិឲ្យចុងចម្លើយ លោកមេធាវី [redacted] បានធ្វើសេចក្តីថ្លែងការណ៍ នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ថា៖** ឆ្លងនីតិវិធីត្រៀមលើកមុន តុលាការបានកំណត់ចំណុចគ្មានវិវាទ គឺប្រាក់ដើម។ ចំនុចវិវាទ ទាក់ទងនឹងអត្រាការប្រាក់ ប្រាក់ឃឹតយ៉ាវ និងសំណងខូចខាត។ កូនក្តីខ្ញុំគ្មានចេតនាគេចវេសពីការមិនសងនោះទេ។ កម្ចីនេះ គឺជាកម្ចីធ្វើជំនួញ ហើយគាត់បានដាក់ប្លង់ដីមកបញ្ចាំធនាគារ ថែមទៀតផង។ គាត់បានយកប្រាក់នេះទៅដាំដំណាំនាំចេញទៅប្រទេសថៃ ។ ក្នុងចំនោមប្រាក់កំចីនេះ កូនក្តីខ្ញុំបានបង់ប្រាក់ទៅធនាគារចំនួន ៣ ម៉ឺនដុល្លារអាមេរិកហើយ ព្រមទាំងបានបង់ទៀងទាត់ថែមទៀត។ សព្វថ្ងៃនេះ ស្ថានភាពកូវីត និងច្រកចេញចូលប្រទេសថៃ បានបិទធ្វើឲ្យសេដ្ឋកិច្ចរបស់កូនក្តីខ្ញុំមានបញ្ហា ។ ទើបកូនក្តីខ្ញុំខកខានបង់។ ជាក់ស្តែង កូនក្តីបានព្យាយាមបង់ប្រាក់ដើមក្នុងមួយឆ្នាំម្តង តែក្រោយមកគាត់បានខកខាតមែន តែកូនក្តីខ្ញុំបានព្យាយាមបង់ការប្រាក់រហូតមក ដល់ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២។ កូនក្តីខ្ញុំពិតជាគ្មានចេតនាគេចវេសទេ។ កូនក្តីខ្ញុំបានព្យាយាមចរចារជាមួយនឹងធនាគារ ឲ្យកូនរបស់គាត់រកប្រាក់បាន ១ម៉ឺនដុល្លារអាមេរិក មកសង តែធនាគារមិនព្រមទទួល។ ហើយគាត់បានប្រកាសលក់ដី តែលក់មិនដាច់។ រដ្ឋាភិបាលក៏បានប្រកាសឲ្យធនាគារយោគយល់ដល់អតិថិជនក្នុងអំឡុងពេលកូវីតនេះដែរ។ កន្លងមក ធនាគារបានចេញដីការក្សាការពារហាមឃាត់ដីរបស់កូនក្តីខ្ញុំ ព្រមទាំងហាមឃាត់ការជួល ដែលធ្វើឲ្យកូនក្តីខ្ញុំប៉ះពាល់ដល់សេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ។ ដូច្នេះ សុំឲ្យតុលាការពិចារណាលើការប្រាក់ និងប្រាក់ឃឹតយ៉ាវរបស់ដើមចោទ ព្រោះកន្លងមកខ្ញុំមិនដែលជួបធនាគារយកអត្រាការប្រាក់ច្រើនបែបនេះ។ ប្រាក់ពិន័យបានចែងកំណត់ ៣ ភាគរយ ក្នុងមួយខែ តើជាការគៀសសង្កាត់ ឬ ជាការសហការ។ ខ្ញុំមិនដែលធនាគារណាខកខានតែ ២ ខែគិតអត្រាការប្រាក់ ៣(បី) ភាគរយ នោះទេ ដែលធ្វើឲ្យប៉ះពាល់ដល់កូនក្តីខ្ញុំ។ ដូច្នេះសូមតុលាការពិចារណាអាណិតអាសូរដល់កូនក្តីខ្ញុំ។កូនស្រីគាត់ក៏បានព្យាយាមខ្ចីធនាគារផ្សេងមកសងធនាគារអេសប៊ីអាយបេបឃ្ល ដែរ តែគេមិនអោយ។ ទើបធ្វើឲ្យមានការខកខានបែបនេះ។ ស្នើសុំតុលាការពិចារណាលើបញ្ហាកូវីត និងបញ្ហាសកល ហើយស្នើសុំច្រានចោលលើចំណុចទាមទារសំណងការខូចខាត។

-ភាគីអ្នកតំណាងដោយអាណត្តិឲ្យចុងចម្លើយ លោកមេធាវី [redacted] បានធ្វើសេចក្ដីថ្លែងការណ៍នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ថា៖ ខ្ញុំឯកភាពតាមសហភាគីរបស់ខ្ញុំ។

**ខ.៤.សេចក្ដីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ**

-ភាគីអ្នកតំណាងដោយអាណត្តិឲ្យដើមចោទឈ្មោះ [redacted] បានធ្វើសេចក្ដីថ្លែងការណ៍នៅថា៖ ចុងចម្លើយបានខកខានអនុវត្តកាតព្វកិច្ច ២ឆ្នាំហើយ។ ការប្រាក់ ១៤.៤ ភាគរយ ក្នុងមួយឆ្នាំ គឺត្រឹមត្រូវតាមច្បាប់កំណត់ គឺប្រកាសលេខ ១២៨ កយ.ប្រក /១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ស្ដីពីការអត្រាការប្រាក់ដែលត្រូវកម្រិតរបស់ក្រសួងយុត្តិធម៌។ ការកំណត់ប្រាក់ឃឹតយ៉ាវ ក៏កើតឡើងដោយការព្រមព្រៀងគ្នា ដោយសេរីរវាងគូភាគី ដោយឈរលើគោលការណ៍ស្វ័យភាពឆន្ទៈរបស់គូភាគី (មាត្រា ៣ នៃក្រមរដ្ឋប្បវេណី) និងលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យា និងអានុភាពនៃកិច្ចសន្យាកើតឡើងនៅពេលសំណើរ និងស្និការត្រូវគ្នា (មាត្រា ៣៦៦ នៃក្រមរដ្ឋប្បវេណី) ។ ចុងចម្លើយមិនអាចលើក ឡើងពីករណីប្រធានសក្តិ ដើម្បីរួចផុតពីកាតព្វកិច្ចនោះទេ ដោយហេតុថា ករណីប្រធានសក្តិច្បាបបានកំណត់ទុកជាមុនតាមមាត្រា ៣៩៩ នៃក្រមរដ្ឋប្បវេណី។

**គ. អង្គហេតុដែលគ្មានវិវាទ៖**

១-គូភាគីទទួលស្គាល់អង្គហេតុបានចុះកិច្ចសន្យខ្ចីបរិភោគចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៨ ជាមួយនឹង **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ [redacted] សាខា ស្រុមរតនមណ្ឌល និង [redacted] សាវៀន និង [redacted] ស៊ីម៉ុន។**

**២.** ចុងចម្លើយទទួលស្គាល់ការទាមទារប្រាក់ដើមចំនួនរបស់ដើមចោទ។

**៣.** គូភាគីទទួលស្គាល់ថា សហចុងចម្លើយបានខកខានបង់ការប្រាក់មកដើមចោទ ចាប់ពីថ្ងៃទី**២៥ ខែឧសភា ឆ្នាំ២០២១ ។**

**ឃ. ចំណុចវិវាទ៖**

១.តើការប្រាក់ចំនួន ២៧៩៥ (ពីរពាន់ប្រាំពីររកៅសិបប្រាំបួន ) ដុល្លារអាមេរិក និង ការប្រាក់ឃឹតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច គិតជាអត្រាការប្រាក់ ៣% (បី) ភាគរយ ក្នុងមួយខែ គិតចាប់ពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ រហូតដល់សងរួច ត្រឹមត្រូវដែរឬទេ ?

២.តើការទាមទារសំណងការខូចខាត និងជំងឺចិត្ត ចំនួន ៤០,០០០,០០០ រៀល ត្រឹមត្រូវ ដែរឬទេ?

**ការពិនិត្យភស្តុតាង**

**១. ភស្តុតាងជាឯកសាររបស់ដើមចោទ៖**

១.១ ប័ណ្ណដកប្រាក់ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ [redacted] ចំនួន ២ច្បាប់។

១.២ តារាងកាលវិភាគសងប្រាក់កម្ចី របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ [redacted]។

១.៣ កិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៨ រវាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ [redacted] និងឈ្មោះ [redacted] សាវឿន និង [redacted] ស៊ីម៉ុន។

១.៤ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ បប ០១២១៨៥ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១១។

១.៥ កិច្ចសន្យាហ៊ីប៉ូតែក ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨ រវាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ [redacted] និងឈ្មោះ [redacted] សាវឿន និង [redacted] ស៊ីម៉ុន។

១.៦ លិខិតអញ្ជើញ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២។

១.៧ លិខិតជូនដំណឹង ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១។

១.៨. កំណត់ហេតុដោះស្រាយបំណុល ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២។

**២. ភស្តុតាងជាឯកសាររបស់សហចុងចម្លើយ ៖**

(គ្មាន)

**សំអាងហេតុ**

ផ្អែកតាមលទ្ធផលនៃការសាកសួរភាគី និងពិនិត្យក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ យល់ឃើញថា៖

១-តាមសេចក្តីថ្លែងការណ៍របស់ភាគី និងការពិនិត្យភស្តុតាងជាឯកសាររួមមាន តារាងកាលវិភាគសងប្រាក់កម្ចី របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ[redacted] កិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៨ រវាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ[redacted] និងឈ្មោះ [redacted] សារឿន និង [redacted] ស៊ីម៉ុន, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ បប ០១២៦៨៥ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១១, កិច្ចសន្យាហ៊ីប៉ូតែក ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨ រវាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ[redacted] និងឈ្មោះ[redacted]សារឿន និង [redacted]ស៊ីម៉ុន និងលិខិតអញ្ជើញលេខ ០២៥ /០៤២២ ក.ម.ល.ស ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ ឃើញថា សហចុងចម្លើយឈ្មោះ អ៊ុ សារឿន និងឈ្មោះ [redacted]ស៊ីម៉ុន ពិតជាបានខ្ចីប្រាក់ពីគ្រឹះស្ថានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ[redacted] (បច្ចុប្បន្នជា ធនាគារ[redacted]) ដែលមានទឹកប្រាក់កម្ចីដើមចំនួន USD ១៥០.០០០ (មួយរយហាសិបពាន់ដុល្លារអាមេរិក ) ក្នុងរយៈពេល ៧៦ ខែ អត្រាការប្រាក់ ១,២ ភាគរយ ក្នុងមួយខែ ដោយរបៀបត្រូវបង់តែការប្រាក់រាល់ខែ ប្រាក់ដើម គឺសងខែ ៥ ឆ្នាំ២០១៨ សងដើមចំនួន ១០.០០០ USD , ខែ០៥ ឆ្នាំ២០១៩ សងដើមចំនួន ២៣.៣៣៤ USD ,ខែ ៥ ឆ្នាំ២០២១ សងដើមចំនួន ២៣.៣៣៤ USD, ខែ ៥ ឆ្នាំ២០២២ សងដើមចំនួន ២៣.៣៣៤ USD, ខែ ៥ ឆ្នាំ២០២៣ សងដើមចំនួន ២៣.៣៣៤ USD និងខែ ៥ ឆ្នាំ២០២៤ សងដើម ចំនួន ២៣.៣៣០ USD។ បន្ទាប់មក សហចុងចម្លើយបាន បានអនុវត្ត កាតព្វកិច្ច បង់ប្រាក់តាមតារាងបង់ប្រាក់មកឲ្យទៅធនាគារ[redacted] ជារៀងរហូតមក ទើបតែ មកដល់ ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ ស្រាប់តែសហចុងចម្លើយបានខកខាន យឺតយ៉ាវ និងពុំបានអនុវត្តបង់ប្រាក់ឲ្យ ធនាគារ[redacted] ដោយសហចុងចម្លើយនៅជំពាក់នូវប្រាក់ដើមសរុបចំនួន USD ១១៦.៦៦៦ (មួយសែនមួយម៉ឺនប្រាំមួយពាន់ប្រាំមួយរយហុកសិបប្រាំមួយ) ដុល្លារអាមេរិក ។ ចំពោះប្រាក់កម្ចីនៅសល់ចំនួន USD ១១៦.៦៦៦ (មួយសែនមួយម៉ឺនប្រាំមួយពាន់ប្រាំមួយរយហុកសិបប្រាំមួយ) ដុល្លារអាមេរិក សហចុងចម្លើយបានក៏ទទួលស្គាល់ផងដែរ ។ ដូច្នេះ អង្គហេតុនេះ គូភាគីទទួលស្គាល់ ពុំមានវិវាទទេ។

២.តាមសេចក្តីថ្លែងការណ៍របស់ដើមចោទ បានប្តឹងទាមទារការប្រាក់ចំនួន ២៧៩៩ $ (ពីរពាន់ប្រាំពីររយកៅសិបប្រាំបួន) ដុល្លារអាមេរិក ដែលជាការប្រាក់គិតថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២១ នៃអត្រាការប្រាក់ ១,២ (មួយក្បៀសពីរ) ភាគរយ ក្នុងមួយខែ នៃប្រាក់ដើមដែលនៅជំពាក់ ចំណែកមេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍បដិសេធនូវការទាមទារនេះ ដោយហេតុថា កូនក្តីខ្លួនគ្មានចេតនាគេចវេសពីការមិនសងនោះទេ ដោយកម្ចីនេះ គឺជាកម្ចីធ្វើជំនួញ ហើយគាត់បានដាក់ប្លង់ដីមកបញ្ចាំធនាគារ ថែមទៀតផង។ គាត់បានយកប្រាក់នេះទៅដាំជំណាំនាំចេញទៅប្រទេសថៃ ហើយសព្វថ្ងៃនេះ ស្ថានភាពកូវីត និងច្រកចេញចូលប្រទេសថៃ បានបិទធ្វើឲ្យសេដ្ឋកិច្ចរបស់កូនក្តីខ្លួនមានបញ្ហា ហើយខ្លួនមិនដែលបានឃើញធនាគារណាយកអត្រាការប្រាក់ច្រើនបែបនេះឡើយ។

តុលាការពិចារណាឃើញថា ចុងចម្លើយបានអះអាងខាងលើ ពុំមានដាក់ភស្តុតាងមកតុលាការពិនិត្យ និងពិចារណា ឡើយ។ គប្បីតុលាការយល់ឃើញថា គូភាគីពិតជាបានព្រមព្រៀងគ្នា ក្នុងអត្រាការប្រាក់ ១,២ ភាគរយ ក្នុងមួយខែ ដូចក្នុងកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៨ រវាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ[redacted] និងឈ្មោះ [redacted] សារឿន និង [redacted] ស៊ីម៉ុន ប្រាកដ មែន ហើយការព្រមព្រៀងគ្នាត្រង់ចំណុចការប្រាក់នេះ ហើយសហចុងចម្លើយបានខកខានក្នុងការបង់ការប្រាក់ចាប់ពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២១ ប្រាកដមែន ស្របតាមមាត្រា ៥៨៣ (សិទ្ធិលើបំណុលដែលជាការប្រាក់) មាត្រា ៣៩៩ (បទបញ្ញត្តិពិសេសអំពីកាតព្វកិច្ចជាប្រាក់) និងមាត្រា ៥៩១ (ករណីយកិច្ចត្រូវសងប្រាក់ដើម និងបង់ការប្រាក់របស់អ្នកខ្ចី) នៃក្រមរដ្ឋប្បវេណី និងប្រកាសលេខ ១២៨ កយ.ប្រក /១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ស្តីពីការអត្រាការប្រាក់ដែលត្រូវកម្រិតរបស់ក្រសួងយុត្តិធម៌ ។

៣.ចំពោះការទាមទារប្រាក់សំណងការខូចខាត ចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច គិតពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២១ លើអត្រាការប្រាក់ ៣ % (បីភាគរយ) ក្នុងមួយខែ នៃប្រាក់ដើមដែលនៅជំពាក់

រហូតដល់ថ្ងៃសងគ្រប់ចំនួន របស់ដើមចោទ ដោយបានថ្លែងការណ៍ថា ការកំណត់ប្រាក់យឺតយ៉ាវ ក៏កើតឡើងដោយការព្រមព្រៀងគ្នា ដោយសេរីរវាងគូភាគី ដោយឈរលើគោលការណ៍ស្វ័យភាពឆន្ទៈរបស់គូភាគី (មាត្រា ៣ នៃក្រមរដ្ឋប្បវេណី) និងលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យា និងអានុភាពនៃកិច្ចសន្យាកើតឡើងនៅពេលសំណើរ និងស្និការត្រូវគ្នា (មាត្រា ៣៦៦ នៃក្រមរដ្ឋប្បវេណី) ។ ចុងចម្លើយមិនអាចលើក ឡើងពីករណីប្រធានសក្តិ ដើម្បីរួចផុតពីកាតព្វកិច្ចនោះទេ ដោយហេតុថា ករណីប្រធានសក្តិច្បាប់បានកំណត់ទុកជាមុនតាមមាត្រា ៣៩៩ នៃក្រមរដ្ឋប្បវេណី។ ចំនែកមេធាវីតំណាងដោយអាណត្តិឲ្យសហចុងចម្លើយ បានថ្លែងការណ៍តបវិញថា កូនក្តីបានខកខាតក្នុងបង់សងទៅធនាគារ[redacted]ដោយសារស្ថានភាពកន្លងមកកូនក្តីខ្លួនមានមុខរបរជាំដំណាំតាងែន ហើយគាត់មានបញ្ហាជួបប្រទះនិងបញ្ហាគ្មានទីផ្សារ និងមានការបិទព្រំដែននៅក្នុងអំឡុងពេលដែលមានវិការលេជាលេកូវីត ១៩ ហើយកូនក្តីជាចុងចម្លើយក៏បានព្យាយាមក្នុងការដោះស្រាយជាមួយនឹងដើមចោទដែរ តែគ្មានលទ្ធភាព និងស្នើសុំតុលាការពិចារណាលើបញ្ហាកូវីត និងបញ្ហាសកលហើយស្នើសុំច្រានចោលលើចំណុចទាមទារសំណងការខូចខាត។

-តុលាការពិចារណា និងពិនិត្យភស្តុតាងរបស់ដើមចោទបានដាក់មកតុលាការ ឃើញថា ភស្តុតាងគ្រប់គ្រាន់ដែលអាចឲ្យបញ្ជាក់ថា សហចុងចម្លើយបានខកខានមិនបានបំពេញកាតព្វកិច្ចក្នុងការបង់ ប្រាក់ដើមនិងការប្រាក់ ដូចមានចែងនៅក្នុងកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៨ ដោយនៅប្រការ៧ លក្ខខណ្ឌពិន័យចំពោះការយឺតយ៉ាវ ៧.១ **ក្នុងករណីភាគី ខ សងកម្ចីយឺតយ៉ាវ ក្រោយថ្ងៃកំណត់សងចុងក្រោយនៃកិច្ចសន្យានេះ នឹងត្រូវទទួលការពិន័យក្នុងអត្រាត្រូវនឹង ៣៦ ភាគរយ ក្នុងមួយឆ្នាំ លើប្រាក់ដើមនៅជំពាក់ទាំងអស់ បន្ថែមលើការប្រាក់រហូតទូទាត់ចប់សព្វគ្រប់មកឲ្យភាគី ក វិញ ។ ចំពោះការគណនាប្រាក់ពិន័យសងនេះ ត្រូវកាត់ចូលជាប្រាក់ផាកពិន័យជាមុន បន្ទាប់មក ការប្រាក់ និងបន្ទាប់មក ប្រាក់ដើម។** រហូតមក ដល់បច្ចុប្បន្នពិតប្រាកដមែន ក៏ប៉ុន្តែការទាមទាររបស់អ្នកតំណាងដោយអាណត្តិឲ្យដើមចោទចំនួនអត្រាប្រាក់សំណងការខូចខាត ចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចចំនួន ៣ ភាគរយក្នុងមួយខែ គឺពិតជាមានកម្រិតខ្ពស់ហួសហេតុ ដែលលើសពីច្បាប់កំណត់ គប្បីតុលាការសម្រេចបង្គាប់ឲ្យសហចុងចម្លើយបង់ប្រាក់សំណងការខូចខាត ចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ត្រឹមតែ ១៨ ភាគរយ ក្នុងមួយឆ្នាំនៃប្រាក់ដើម គិតចាប់ពីថ្ងៃទី គិតចាប់ពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១ រហូតដល់សងគ្រប់ចំនួន ស្របតាមដែលស្របតាមមាត្រា ៣៩៨ នៃក្រមរដ្ឋប្បវេណី និងប្រការ ១ នៃប្រកាសលេខ ១២៨ កយ.ប្រក /១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ស្តីពីការអត្រាការប្រាក់ដែលត្រូវកម្រិតរបស់ក្រសួងយុត្តិធម៌ ។

៥- ចំពោះដើមចោទប្តឹងទាមទារសំណងជំងឺចិត្តចំនួន ៤០,០០០,០០០ (សែសិបលាន) រៀល នៅក្នុងអង្គហេតុរឿងក្តី តុលាការឃើញថា ការទាមទាររបស់ដើមចោទនេះពុំមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់អំពីទំហំនៃការខូចខាតច្បាស់លាស់នោះទេ ម៉្យាងវិញទៀត ស្ថានភាពរបស់សហចុងចម្លើយពិតជាមានភាពលំបាកដោយសារតែបញ្ហាសេដ្ឋកិច្ច គប្បីតុលាការពិចារណាត្រឹមកម្រិតដែលសមរម្យ ដោយផ្អែកតាមមាត្រា ៤០០ នៃក្រមរដ្ឋប្បវេណី។

៦-ដើមចោទប្តឹងទាមទារសុំឲ្យតុលាការប្រកាសសាលក្រមនេះ មានអានុភាពអនុវត្តជាបណ្តោះអាសន្នបាន គឺមានមូលហេតុសមរម្យ ដោយហេតុថា ការទាមទាររបស់ដើមចោទ ជាការទាមទារប្រាក់ដែលជាសិទ្ធិលើទ្រព្យសម្បត្តិស្របតាមបញ្ញត្តិមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៧-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ ដែលជាអ្នកចាញ់ក្តី តាមមាត្រា ៦៤ នៃក្រមនីតិវិធីនៃព្រះរាជាណាចក្រកម្ពុជា។

## សេចក្តីសម្រេចបញ្ចប់

១- បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] សារឿន និងប្រពន្ធឈ្មោះ [redacted] ស៊ីម៉ុន រួមគ្នាសងប្រាក់ទៅឲ្យដើមចោទ ដូចខាងក្រោម៖

ក-ប្រាក់ដើមចំនួន **១១៦.៦៦៦** (មួយសែនមួយម៉ឺនប្រាំមួយពាន់ប្រាំមួយរយហុកសិបប្រាំមួយ) ដុល្លារអាមេរិក ។

ខ-ការប្រាក់ **១,២ ភាគរយ** ក្នុងមួយខែ នៃប្រាក់ដើមចំនួន ១១៦,៦៦៦ ដុល្លារអាមេរិក គឺត្រូវគិតថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២១ ស្មើនឹងទឹកប្រាក់ ២៧៩៩ (ពីរពាន់ប្រាំពីររយកៅសិបប្រាំបួន) ដុល្លារអាមេរិក ។

គ-ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចអត្រាការប្រាក់ ១៨ (ដប់ប្រាំបី) ភាគរយ ក្នុងមួយឆ្នាំ នៃប្រាក់ដើមចំនួន ១១៦,៦៦៦ ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០២១ រហូតដល់សងគ្រប់ចំនួន។

២.បង្គាប់ឲ្យសហចុងចម្លើយសងសំណងជំងឺចិត្ត និងសំណងការខូចខាតចំនួន ១២.០០០.០០០ (ដប់ពីរលាន) រៀលឲ្យ ដើមចោទ។

៣-ការទាមទារផ្សេងៗលើសពីនេះរបស់ដើមចោទ ត្រូវបានច្រានចោល។

៤-ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់សហចុងចម្លើយ។

៥-សាលក្រមនេះ មានភាពអនុវត្តបណ្តោះអាសន្នត្រង់ចំណុចទី១ (ក) នៃសេចក្តីសម្រេចបញ្ចប់។

សាលក្រមនេះ ត្រូវបានប្រកាសនៅសាលសវនាការជាសាធារណៈ ,នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ ២០២៣ ។

**ក្នុងករណីដែលប្តឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើងក្នុងរយៈពេល ០១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។**

ថ្ងៃពុធ០៦ រោច ខែពិសាខ ឆ្នាំថោះ បញ្ច ស័ក ព.ស ២៥៦៧
ខេត្តបាត់ដំបង, ថ្ងៃទី១០ ខែឧសភា ឆ្នាំ ២០២៣

**ចៅក្រម**

**ហត្ថលេខា និងត្រា** [redacted]

---

បានឃើញ
**ចៅក្រម**
[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃពុធ០៦ រោច ខែពិសាខ ឆ្នាំថោះ បញ្ច ស័ក ព.ស ២៥៦៧
ខេត្តបាត់ដំបង, ថ្ងៃទី១០ ខែឧសភា ឆ្នាំ ២០២៣
**ក្រឡាបញ្ជី**
[redacted]